# កញ្ញា ឈឹម ស៊ីថរ ជាស្ត្រីទីមួយទទួលពានរង្វាន់សិទ្ធិមនុស្ស ខណៈកំពុងជាប់ឃុំជាលើកទីពីរ។




*មប្រធានសហជីពកាស៊ីណូណាហ្គាវើលដ៍ កញ្ញា ឈឹម ស៊ីថា ចាកចេញពីសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៣។ ខេមបូចា/ ព្រឹង សំរាំង*

ប្រធានសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គាវើលដ៍ កញ្ញា ឈឹម ស៊ីថរ ត្រូវបានក្រសួងការបរទេសសហរដ្ឋអាមេរិកប្រកាសផ្តល់ពានរង្វាន់អ្នកការពារសិទ្ធិមនុស្សប្រចាំឆ្នាំ ក្នុងចំណោម១០នាក់ផ្សេងទៀតជុំវិញពិភពលោក ខណៈកញ្ញា កំពុងជាប់ឃុំខ្លួនជាលើកទីពីរអស់រយៈពេល១០សប្តាហ៍មកហើយ។

តាមរយៈស្ថានទូតអាមេរិកប្រចាំកម្ពុជា បានឱ្យដឹងថា ពានរង្វាន់អ្នកការពារសិទ្ធិមនុស្ស នេះ គឺជាពានរង្វាន់ដ៏មានកិត្យានុភាព ដែលទទួលស្គាល់ទៅលើបុគ្គលទាំងឡាយណា ដែលមានភាពជាអ្នកដឹកនាំ ក្លាហាន តស៊ូ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ដែលមានការទទួលស្គាល់ជាសាកល និងសេរីភាពជាមូលដ្ឋាន។

ក្រសួងការបរទេសសហរដ្ឋអាមេរិក បានប្រកាសកាលពីថ្ងៃទី១ ខែកុម្ភៈ នេះថា កញ្ញា ឈឹម ស៊ីថរ គឺជាអ្នកដឹកនាំសហជីពមួយរូប ដែលបានក្លាយជាម្ចាស់ពានរង្វាន់អ្នក ការពារសិទ្ធិមនុស្សប្រចាំឆ្នាំ។

ស្ថានទូតអាមេរិក បញ្ជាក់ថា៖ *«កញ្ញា គឺជាអ្នកទីមួយ នៃប្រទេសកម្ពុជា ដែលបានពាន រង្វាន់នេះ»។*

ទោះបីជាមានការបៀតបៀនរូបកាយ និងការចាប់ខ្លួនម្តងរួចមកហើយកាលពីខែមករា ឆ្នាំ ២០២២ កញ្ញា ស៊ីថរ បានបន្តចេញមុខនិយាយអំពីសិទ្ធិការងារ។ ប៉ុន្តែក្រោយពេល ដែលអាជ្ញាធរដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន សមត្ថកិច្ច បានចាប់ខ្លួន កញ្ញា ស៊ីថរ ម្តងទៀត នៅខែវិច្ឆិកា ឆ្នាំ២០២២ ដោយចោទថារូបនាងល្មើសបម្រាមនៅក្រៅឃុំ ព្រោះរូបនាងបានទៅប្រទេសអូស្ត្រាលី ចូលរួមសន្និសីទទាក់ទងនឹងសហជីព ។

បើតាមអង្គការលីកាដូ បានឱ្យដឹងថា បច្ចុប្បន្ននេះ កញ្ញា ឈឹម ស៊ីថរ បន្តឃុំខ្លួន បណ្តោះអាសន្នពីបទញុះញង់ អស់រយៈពេលជាង១០សប្តាហ៍មកហើយ បន្ទាប់ពី តុលាការក្រុងភ្នំពេញបានបដិសេធបណ្តឹងសុំនៅក្រៅឃុំរបស់ប្រធានសហជីពប្រចាំ ក្រុមហ៊ុនណាហ្គាវើលដ៍ កាលពីពេលថ្មីៗនេះ។

យ៉ាងណាមិញ កញ្ញា ឈឹម ស៊ីថរ មិនអាចធ្វើដំណើរទៅទទួលរង្វាន់នៅរដ្ឋធានីវ៉ាស៊ី ងតោនបានឡើយ ខណៈរូបនាងកំពុងជាប់ឃុំខ្លួន។ នេះបើតាមស្ថានទូតអាមេរិកប្រចាំ កម្ពុជា។

លោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លើកឡើងថា ការការពារនិងគាំទ្រអ្នកការពារសិទ្ធិមនុស្ស គឺជាអាទិភាពចម្បងនៃគោលនយោបាយការបរទេសសហរដ្ឋអាមេរិក ។ ស្ថានទូតអាមេរិកនៅប្រទេសកម្ពុជា សូមអបអរសាទរដល់កញ្ញា ឈឹម ស៊ីថរ និងអ្នកទទួលទាំងអស់នៃពានរង្វាន់អ្នកការពារសិទ្ធិមនុស្សឆ្នាំ ២០២២ ។

លោក Patrick បានថ្លែងថា៖ *«យើងអបអរចំពោះការទទួលស្គាល់ដល់កញ្ញា ស៊ីថរ ជាអ្នកការពារសិទ្ធិមនុស្សឆ្នាំ ២០២២ ម្នាក់ ។ កញ្ញាគឺជាថ្នាក់ដឹកនាំសហជីពការងារដ៏ក្លាហាននិងអត់ធ្មត់ ដែលតស៊ូមតិដោយសន្តិវិធីដើម្បីសិទ្ធិរបស់កម្មករកម្ពុជា»*។

លោក សំ ចំរើន មេធាវីការពារក្តីឱ្យកញ្ញា ឈឹម ស៊ីថរ ថ្លែងថា លោកនឹងពាំនាំដំណឹងនេះទៅកាន់កូនក្តីលោកនៅមណ្ឌលកែប្រែម១នៃពន្ធនាគារព្រៃសនៅពេលឆាប់ៗខាងមុខនេះ បើទោះបីកូនក្តីរបស់លោកកំពុងជាប់ឃុំខ្លួនក៏ដោយ។

លោក ចំរើន ថ្លែងថា៖ *«ចាំមើលលំមើល! ខ្ញុំឮល្បៀងៗដែរ បើជាផ្លូវការខ្ញុំនឹងពាំនាំដំណឹងហ្នឹងទៅប្រាប់គាត់»*។

មេធាវីរូបនេះ បន្ថែមថា នៅក្នុងសំណុំរឿងកញ្ញា ឈឹម ស៊ីថរ តុលាការបានប្រកាសថានឹងមានសវនាការអង្គសេចក្តីនៅថ្ងៃទី២១ ខាងមុខនេះ។

លោកមេធាវីបញ្ជាក់ថា៖ *«យើងបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ហើយតុលាការបានជូនដំណឹងសវនាការអង្គសេចក្តីហើយ»*។

ចំណែកលោកស្រីចក់ សុភាព នាយិការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានសម្តែងការសាទរ ទៅកាន់កញ្ញា ស៊ីថរ ចំពោះការទទួលបានពានរង្វាន់អ្នកការពារសិទ្ធិមនុស្សនេះ តែអ្នកស្រីមានការសោកស្តាយខណ: ស្ត្រីឆ្នើមដែលចេញមុខទាមទារសិទ្ធិការងារកំពុងជាប់ឃុំខ្លួននៅឡើយ។

លោកស្រីថ្លែងថា៖ *«ជារឿងមួយដែលសក្តិសម ភាពអង់អាច ការលះបង់ និងឆន្ទៈមោះមុតនេះជាការសក្តិសមណាស់ ដែល ស៊ីថរ ទទួលបានការកោតសរសើរចំពោះវីរៈភាពនេះ»*។

អ្នកស្រី សុភាព លើកឡើងថា រដ្ឋាភិបាលកម្ពុជាពុំគួរចាត់ទុកសកម្មជន ឬអ្នកការពារសិទ្ធិមនុស្សជាសត្រូវនោះទេ ហើយគួរទទួលស្គាល់ និងលើកតម្កើង បង្កើតឱ្យមានការប្រគល់ពានរង្វាន់សិទ្ធិមនុស្សនៅកម្ពុជា និងបង្ហាញពីការគាំពារពេញលេញទៅលើបុគ្គលទាំងនោះ ពីភាគីរដ្ឋាភិបាល។

លោកស្រី សុភាព បន្ថែមថា៖ *«កន្លងមកការទទួលស្គាល់ និងការឱ្យតម្លៃទៅលើសកម្មជនហ្នឹង មានតែពីរដ្ឋាភិបាលក្រៅប្រទេស កម្រឃើញរដ្ឋាភិបាលយើងទទួលស្គាល់ឱ្យតម្លៃ»*។

បើតាមស្ថានទូតអាមេរិក កញ្ញា ស៊ីថរ បានដឹកនាំបុគ្គលិកកម្មករក្រុមហ៊ុនណាហ្គាវើលដ៍ធ្វើកូដកម្មដោយសន្តិវិធី ក្នុងឆ្នាំ២០២១ ដោយ អំពាវនាវឱ្យមានប្រាក់ខែខ្ពស់ និងទទួលយកបុគ្គលិកជាសមាជិកសហជីពរាប់រយនាក់ ដែលជឿថាពួកគេត្រូវបានបណ្ដេញចេញពីការងារទាំងអយុត្តិធម៌ ដោយរាប់ទាំង ថ្នាក់ដឹកនាំសហជីពចំនួនជាង១០រូប កំពុងប្រឈមនូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ទាក់ទងនឹងរឿងកូដកម្មនេះ៕